# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ២០៤/០៥ **គ.ជ.ប**.[illegible]

**សេចក្ដីសម្រេច**

**ស្ដីពី**

**ការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤**

**ថ្ងៃ អាទិត្យ ទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/៣០៥ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- បានឃើញបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- បានឃើញបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ។
- យោងប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ឆ្នាំ ២០០៨ ។
- យោងទម្រង់បែបបទ ១១០១ និង ១១០២ របស់ គ.ក.ប ១១០៥ និង ១១០៣ របស់ គឃ/សប និងទម្រង់ ១១១០ និង ១១១១ របស់ គខ/កប ។
- យោងរបាយការណ៍ និងទម្រង់បែបបទ ១១១៧ គព របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ។
- យោងសេចក្ដីជូនដំណឹងរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ២១/២០០៨ កបធ.សជណ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៨ ស្ដីពីការបញ្ចប់ការដោះស្រាយបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ។

**<u>ស ម្រេ ច</u>**

**ប្រការ ១ :** ប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ដែលមានលទ្ធផលជាតួលេខដូចក្នុងតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតតាមខេត្ត ក្រុងទូទាំងប្រទេស (ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨) ភ្ជាប់មកជាមួយ ។

**ប្រការ ២ :** លទ្ធផលផ្លូវការនៃការបោះឆ្នោតដូចប្រការ ១ មានអានុភាពតតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ ៣ :** អគ្គលេខាធិការ គ.ជ.ប ត្រូវផ្សព្វផ្សាយលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ជាសាធារណៈឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ។

ភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៨

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

អ៊ឹម_សួស្ដី

<u>ចម្លងថ្វាយ</u>

- ព្រះមហាក្សត្រ

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា
- រាជរដ្ឋាភិបាល
- គណបក្សនយោបាយ "ដើម្បីជូនជ្រាប"
- មជ្ឈមណ្ឌលព័ត៌មានសារជាតិ
- ឯកសារ កាលប្បវត្តិ